# ធនាគារជាតិនៃកម្ពុជា




ធនាគារជាតិនៃកម្ពុជា សាខាខេត្តរតនៈគីរី

# របាយការណ៍ប្រចាំឆ្នាំ
# ២០១១

អគ្គនាយកដ្ឋានត្រួតពិនិត្យ



# អារម្ភកថា

នៅក្នុងឆ្នាំ២០១១កន្លងទៅ ប្រទេសអភិវឌ្ឍ និងប្រទេសដែលមានសេដ្ឋកិច្ចទើបនឹងរីកលូតលាស់ បានទទួលរងនូវផលប៉ះពាល់ដោយវិបត្តិមួយចំនួនរួមមាន វិបត្តិបំណុលសាធារណៈ ដែលមានសភាពធ្ងន់ធ្ងរក្នុងតំបន់អឺរ៉ុប អត្រានិកម្មភាពខ្ពស់ ជំនឿទុកចិត្តរបស់សាធារណៈជនមានកំរិតទាប ខណៈពេលដែលការស្តារឡើងវិញពីគ្រោះធម្មជាតិនៅកំពុងបន្តនៅឡើយ ។ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០១១ បានថយចុះចំនួន ១,១% ធៀបទៅនឹងឆ្នាំ២០១០ ដែលមានអត្រា ៤% ។

ប្រទេសកម្ពុជានៅរក្សាបានសន្ទុះក្នុងការអភិវឌ្ឍនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួនក្នុងឆ្នាំកន្លងទៅទោះបីទទួលរងវិបត្តិសេដ្ឋកិច្ចពិភពលោក និងជាពិសេសគ្រោះធម្មជាតិទឹកជំនន់ប៉ះពាល់ផ្នែកខ្លះនៃប្រទេសក៏ដោយ ។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុ អន្តរការីយកម្មនៃវិស័យធនាគារបានបង្ហាញនូវការវិវឌ្ឍន៍ដ៏គួរឲ្យកត់សំគាល់ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនូវចំនួនគ្រឹះស្ថានធនាគារ និងបណ្តាញសាខាក្នុងឆ្នាំកន្លងមក ។ ក្នុងឆ្នាំកន្លងទៅ ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុសម្រេចបានលទ្ធផលគួរជាទីគាប់ចិត្ត។ មូលដ្ឋានគ្រឹះនៃដើមទុនរបស់វិស័យធនាគារត្រូវបានពង្រឹងតាមរយៈការបង្កើននូវដើមទុនដោយគ្រឹះស្ថានធនាគារ ចំណែកស្ថានភាពសន្ទនីយភាពអាចរក្សាបានលើកម្រិតកំណត់ដោយបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។ និន្នាការនៃទ្រព្យសកម្ម និងលទ្ធភាពរកប្រាក់ចំណេញរបស់គ្រឹះស្ថានធនាគារក៏មានការកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៩ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅតែដើរតួនាទីយ៉ាងសំខាន់ ដែលជួយជ្រោមជ្រែងដល់ប្រជាជនតាមតំបន់ជនបទ ក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ច ។ ក្នុងឆ្នាំ២០១១ ការឲ្យខ្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើងប្រហែល ៥០% ស្របពេលដែលប្រាក់សន្សំមាននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើងប្រហែល ៣ ដងធៀបទៅនឹងឆ្នាំ២០១០ ។

ខណៈដែលវិស័យហិរញ្ញវត្ថុកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ នៅមានលទ្ធភាពជាច្រើនទៀតសម្រាប់ការអភិវឌ្ឍសំខាន់ៗទាំងកំរិតឧស្សាហកម្ម ក៏ដូចជាកំរិតបទប្បញ្ញត្តិ និងការត្រួតពិនិត្យ ។ នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដែលដើរតួជាផែនការ១០ឆ្នាំ (២០០១-២០១០) និងទិសដៅសម្រាប់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ព្រមទាំងសម្រាប់ការអភិវឌ្ឍសមត្ថភាព គតិយុត្ត និងបទប្បញ្ញត្តិក្នុងវិស័យហិរញ្ញវត្ថុរបស់ប្រទេស ។ ចាប់តាំងពីពេលនោះមក យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលក្នុងស្រុក ក៏ដូចជាទិដ្ឋភាពនៃប្រព័ន្ធហិរញ្ញវត្ថុសកលលោក ។ ក្នុងឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងក្រសួង និងអាជ្ញាធរពាក់ព័ន្ធ បានពិនិត្យលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ ។ ការធ្វើបច្ចុប្បន្នកម្មនេះ គ្រោងនឹងដាក់ឲ្យដំណើរការជាផ្លូវការនៅក្នុងឆ្នាំ២០១២ ។

ដើម្បីសម្រេចបាននូវប្រសិទ្ធភាពក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ និងមានតួនាទីជាបញ្ញត្តិករ ធនាគារជាតិនៃកម្ពុជាបានធ្វើការកែសម្រួលរចនាសម្ព័ន្ធនិងធ្វើឲ្យប្រសើរឡើងនាយកដ្ឋានត្រួតពិនិត្យ ដែលបានប្រែក្លាយទៅជាអគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលរួមមាន ៤ នាយកដ្ឋាន ៖ នាយកដ្ឋានត្រួតពិនិត្យលើឯកសារ នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង នាយកដ្ឋានគតិយុត្តិ និងនាយកដ្ឋានអាជ្ញាប័ណ្ណ ។ ចំនួនមន្ត្រី-បុគ្គលិកសរុបមានការកើនឡើងពី ៦៤ រូបនៅក្នុងឆ្នាំ២០០៩ ដល់ ៨២ រូបនៅក្នុងឆ្នាំ២០១១ ដែលរួមទាំងមន្ត្រីបុគ្គលិកដែលទើបជ្រើសថ្មី និងមន្ត្រីបុគ្គលិកដែលផ្ទេរពីនាយកដ្ឋានផ្សេងៗ ។ មន្ត្រីបុគ្គលិកទាំងនេះត្រូវបានទទួលការបណ្តុះបណ្តាលជាប្រចាំពីជំនាញការអន្តរជាតិ ទាំងនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេស ។

ដើម្បីអនុលោមទៅតាមបទដ្ឋានអន្តរជាតិ និងសម្របសម្រួលទៅតាមការផ្លាស់ប្តូរនៃបរិយាកាសហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកំពុងធ្វើការសិក្សាកែសម្រួលឡើងវិញនូវបទប្បញ្ញត្តិប្រុងប្រយ័ត្ន ដែលបានដាក់ចេញឲ្យអនុវត្តនាពេលកន្លងមក និងចេញផ្សាយនូវបទប្បញ្ញត្តិថ្មីៗ ដើម្បីធានាថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើប្រតិបត្តិការប្រកបដោយសុវត្ថិភាពនិងភាពរឹងមាំ ។ ការដាក់ឲ្យអនុវត្តនូវបទប្បញ្ញត្តិទាំងនេះ នឹងជួយពង្រឹងការអភិវឌ្ឍគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្ថែមទៀត ស្របពេលដែលប្រទេសកម្ពុជា កំពុងធ្វើសមាហរណកម្មកាន់តែសកម្មនៅក្នុងតំបន់ និងទីផ្សារពិភពលោក ។

ក្រោមកិច្ចសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ធនាគារជាតិនៃកម្ពុជា សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានបង្កើតក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា (Credit Bureau Cambodia) ។ ការបង្កើតក្រុមហ៊ុននេះឡើង គឺជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការជំរុញគុណភាពឥណទាន តម្លាភាព ជាពិសេសបញ្ចៀសបាននូវហានិភ័យឥណទាន ដែលកើតចេញមកពីការផ្តល់ឥណទានត្រួតគ្នាដល់អ្នកខ្ចីតែម្នាក់ពីគ្រឹះស្ថានផ្សេងៗ ។

សរុបមក សកម្មភាពក៏ដូចជាការសម្រេចបានរបស់គ្រឹះស្ថានធនាគារក្នុងឆ្នាំ២០១១ បានរួមចំណែកដល់ការអភិវឌ្ឍនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាក៏ដូចជាកំណើនសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី បញ្ហាប្រឈមថ្មីៗទាំងឡាយបានផុសឡើង និងតម្រូវឲ្យមានការត្រួតពិនិត្យយ៉ាងដិតដល់ពីសំណាក់អាជ្ញាធរត្រួតពិនិត្យ ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តអនុវត្តមុខងារត្រួតពិនិត្យ និងបញ្ញត្តិកររបស់ខ្លួនប្រកបទៅដោយភាពប្រុងប្រយ័ត្ន ដោយរួមបញ្ចូលវិធានត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ។ ដោយការអនុវត្តន៍នូវមុខងារទាំងនេះ ទាមទារនូវមន្ត្រីត្រួតពិនិត្យដែលមានជំនាញនិងបទពិសោធន៍ ការពង្រឹងការកសាងសមត្ថភាពរបស់មន្ត្រី-បុគ្គលិកនៅតែជាគោលដៅអាទិភាពមួយសម្រាប់ធនាគារជាតិនៃកម្ពុជា ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជា បន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការទ្វេរភាគីជាមួយអាជ្ញាធរត្រួតពិនិត្យនៃបណ្តាប្រទេសផ្សេងៗ ក្នុងការចែករំលែកព័ត៌មាននិងការផ្លាស់ប្តូរបទពិសោធន៍ ។ ទោះបីជាមានឧបសគ្គ និងការប្រឈមនានា ធនាគារជាតិនៃកម្ពុជាបានត្រៀមខ្លួនជាស្រេច និងតាំងចិត្តអនុវត្តសម្រេចឲ្យបានដើម្បីធានាសុវត្ថិភាព និងភាពរឹងមាំនៃប្រព័ន្ធធនាគារ ។

ភ្នំពេញ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២

**ជា ចាន់តូ**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

# មាតិកា


១. រចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារ ..... ១

២. ប្រតិបត្តិការក្នុងវិស័យធនាគារ ..... ១

៣. ប្រតិបត្តិការក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ..... ២

៤. ការអភិវឌ្ឍក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារ ..... ៤

៤.១. ការអភិវឌ្ឍផ្នែកបទប្បញ្ញត្តិ ..... ៤

៤.២. ការអភិវឌ្ឍផ្នែកត្រួតពិនិត្យ ..... ៤

៤.៣. ការអភិវឌ្ឍនៃសេវាកម្ម និងផលិតផលហិរញ្ញវត្ថុ ..... ៥

៤.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ..... ៥

៥. ហានិភ័យ និងភាពងាយរងគ្រោះ ..... ៥

៥.១. ហានិភ័យឥណទាន ..... ៥

៥.២. ហានិភ័យសន្ទនីយភាព ..... ៧

៥.៣. ហានិភ័យប្រតិបត្តិការ ..... ៨

៥.៤. លទ្ធភាពស្វែងរកប្រាក់ចំណេញ ..... ៨

៥.៥. ដើមទុន ..... ៩

៦. បញ្ហា និងការប្រឈម ..... ៩

៧. សេចក្តីសន្និដ្ឋាន ..... ១០

ឧបសម្ព័ន្ធទី១ : ទិន្នន័យរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឆ្នាំ ២០១១ ..... ១១

ឧបសម្ព័ន្ធទី២ : ឆិវ្វា ការអត្រាការប្រាក់ ..... ១២

ឧបសម្ព័ន្ធទី៣ : ប្រព័ន្ធធនាគារនៅកម្ពុជា ..... ១៤

## ទិន្នន័យទាំងអស់មិនបានធ្វើសវនកម្ម និងរាយការណ៍ដោយ
## គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ១. រចនាសម្ព័ន្ធនៃប្រព័ន្ធធនាគារ

គិតត្រឹមដំណាច់ឆ្នាំ២០១១ វិស័យធនាគារក្នុងប្រទេសកម្ពុជារួមមានធនាគារពាណិជ្ជចំនួន ៣១ ដែលក្នុងនោះ ធនាគារចំនួន ២២ ត្រូវបានបង្កើតឡើងក្នុងស្រុក និងធនាគារចំនួន ៩ ជាសាខាធនាគារបរទេស ធនាគារឯកទេស មានចំនួន ៧ ក្នុងនោះធនាគារគ្រប់គ្រងដោយរដ្ឋមានចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណចំនួន ៣២ ដែលគ្រឹះស្ថានចំនួន ៧ អាចប្រមូលប្រាក់បញ្ញើពីអតិថិជន និងប្រតិបត្តិករមីក្រូហិរញ្ញវត្ថុចុះបញ្ជីចំនួន ២៩ ។ យោងតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារទាំងអស់ក្នុងប្រទេសកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នដូចៗគ្នា ដោយមិនមានការបែងចែកនូវរូបភាពផ្លូវច្បាប់ថាជាធនាគារក្នុងស្រុក ឬសាខាធនាគារបរទេសនោះឡើយ ។

## ២. ប្រតិបត្តិការក្នុងវិស័យធនាគារ

វិស័យធនាគារក្នុងឆ្នាំ២០១១ មានការរីកចំរើនគួរឲ្យកត់សម្គាល់ ។ ទ្រព្យសកម្មសរុប បានកើនឡើង ២៤,៣៩% ធៀបទៅនឹងឆ្នាំមុន ស្របគ្នានេះកំណើនឥណទានមានចំនួន ៣៣% ឬស្មើនឹង ១.០៨៥ លានដុល្លារអាមេរិក ។ កំណើនឥណទាននេះ គឺអាស្រ័យដោយមានកំណើនប្រាក់បញ្ញើចំនួន ២០% ឬស្មើនឹង ៨៨០ លានដុល្លារអាមេរិក និងមូលដ្ឋានដើមទុនមានកំណើនចំនួន ៩,៨៥% ឬស្មើនឹង ១១២ លានដុល្លារអាមេរិក ។ កម្រិតនៃអន្តរការីយកម្មក្នុងវិស័យធនាគារបានកើនឡើងពី ៧៥% ក្នុងឆ្នាំ២០១០ ទៅ ៨៣% ក្នុងឆ្នាំ២០១១ ។ ទ្រព្យសកម្មសរុបធៀបនឹងផលិតផលក្នុងស្រុកសរុបកើនឡើងពី ៥៦% ក្នុងឆ្នាំ២០១០ រហូតដល់ ៦៣% ក្នុងឆ្នាំ២០១១ ។ ឥណទានសរុប និងប្រាក់បញ្ញើសរុបធៀបនឹងផលិតផលក្នុងស្រុកសរុប បានកើនឡើងដល់ ៣៤% និង ៤១% រៀងគ្នាពី ២៨% និង ៣៧% ក្នុងឆ្នាំមុន ។

**ទ្រព្យសកម្មសរុបធៀបនឹងផលិតផលក្នុងស្រុកសរុប**



ប្រតិបត្តិការក្នុងវិស័យធនាគារ ក៏បានបង្ហាញឲ្យឃើញផងដែរនូវការរីកចំរើនគួរឲ្យកត់សំគាល់ចំពោះការពង្រីកនូវបណ្តាញសេវាកម្មរបស់ខ្លួន ។ ទោះបីជាចំនួនអ្នកខ្ចីប្រាក់កើនឡើងតិចតួចត្រឹមតែ ៣% ដែលមានចំនួន ២៩៤.៥៣៣ គណនីក៏ដោយ ចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនឡើងយ៉ាងខ្លាំងរហូតដល់ ១៩% ស្មើនឹង ១.២៦៦.៤១២ គណនីគិតត្រឹមដំណាច់ឆ្នាំ២០១១ ។ ចំនួនបណ្តាញសាខា និងប៉ុស្តិ៍សេវាកម្មរបស់ធនាគារបានកើនឡើងចំនួន ៧,១% ក្នុងឆ្នាំ២០១១ ដែលមានចំនួនរហូតដល់ ៤២១ កន្លែងទូទាំងប្រទេស ។ សេវាកម្មទំនើបផ្នែកធនាគារផ្សេងៗទៀតមាន ដូចជា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន ក៏ត្រូវបានពង្រីកយ៉ាងសកម្មផងដែរ ។ ចំនួនម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិបានកើនឡើងចំនួន ១៧% ដែលសរុបមានចំនួន ៥៨៨ម៉ាស៊ីន ។ ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន ដែលត្រូវបានបោះផ្សាយថ្មីៗក្នុងឆ្នាំ២០១១ មានការកើនឡើងចំនួន ៥៣% ដល់ ២១.៣៦៧ កាត និង ២៩% ដល់ ៧៦១.៨៧៦ កាតរៀងគ្នា បើធៀបទៅនឹងឆ្នាំ២០១០ ។ គិតត្រឹមដំណាច់ឆ្នាំ២០១១ ចំនួនសរុបនៃអ្នកប្រកបអាជីវកម្មប្តូរប្រាក់ទូទាំងប្រទេសមានចំនួន ១.២៩៦ ដែលក្នុងនោះ ៤៧ បានទទួលអាជ្ញាប័ណ្ណ និង ១.២៤៩ បានចុះបញ្ជី ។







## ៣. ប្រតិបត្តិការក្នុងវិស័យមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាបន្តអភិវឌ្ឍជាលំដាប់ទាំងចំនួន ទំហំ និងប្រតិបត្តិការក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យម ក៏ដូចជាប្រជាជនតាមតំបន់ដាច់ស្រយាល ដែលមិនទាន់អាចទទួលបានសេវាកម្មហិរញ្ញវត្ថុពីធនាគារពាណិជ្ជ ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣២ បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដែលក្នុងនោះ ៧ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ ។ ការរីកចំរើននេះ ឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃទ្រព្យសកម្មសរុបក្នុងវិស័យទាំងមូលចំនួន ៤៧,៩៧% ដែលកើនឡើងពីចំនួន ២.០៥១.៤៨៤លានរៀល (៥០៦,១៦លានដុល្លារអាមេរិក) នាដំណាច់ឆ្នាំ២០១០ រហូតដល់ ៣.០២៥.០៨៣ លានរៀល (៧៤៨,៩៧លានដុល្លារអាមេរិក) នាដំណាច់ឆ្នាំ២០១១ ។ វិស័យមីក្រូហិរញ្ញវត្ថុ មិនត្រឹមតែរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទតាមរយៈសេវាកម្មមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ វិស័យនេះក៏បានផ្តល់ឱកាសការងារដល់និស្សិតកម្ពុជាជាច្រើននាក់ ដែលបានបញ្ចប់ការសិក្សាផងដែរ ។

គិតត្រឹមខែធ្នូ ឆ្នាំ២០១១ ចំនួននិយោជិកសរុបដែលបំរើការក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ៩.៧៤៤ នាក់ ដែលក្នុងនោះ ២.៦១៧ នាក់ជាស្ត្រី ។







ជាមួយបរិយាកាសដ៏មានអំណោយផលផ្នែកអាជីវកម្ម បទប្បញ្ញត្តិ និងគោលនយោបាយ វិស័យមីក្រូហិរញ្ញវត្ថុទទួលបានជំនឿទុកចិត្តកាន់តែច្រើនឡើងពីសាធារណៈជន ទាំងម្ចាស់បំណុល និងកូនបំណុល ជាពិសេសពីប្រជាជនក្រីក្រតាមទីជនបទនិងវិនិយោគិនបរទេស ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ដើមទុនបានចុះបញ្ជីសរុបដែលគ្រប់គ្រង ដោយភាគទុនិកកម្ពុជាមានចំនួន ២៣% និងភាគទុនិកបរទេសមានចំនួន ៧៧% ។

ចំនួនឥណទានសរុប បានកើនឡើង ៥០% ពី ១.៧២៤.៨៤១ លានរៀល (៤២៦ លានដុល្លារអាមេរិក) នាដំណាច់ឆ្នាំ២០១០ រហូតដល់ ២.៥៩១.២៦៣ លានរៀល (៦៤១,៥៣ លានដុល្លារអាមេរិក) នាដំណាច់ឆ្នាំ២០១១ ។ ចំនួនអ្នកខ្ចី បានកើនឡើងចំនួន ១៧% ពី ៩៧៨.០៧៧ នាក់ដល់ ១.១៤១.៩១៣ នាក់ ។ បន្ថែមពីនេះ ចំនួនប្រាក់បញ្ញើប្រមូលផ្តុំសរុប បានកើនឡើងជាគំហុកចំនួន ១៨០% ពី ១៦៤.០១៤ លានរៀល (៤១ លានដុល្លារអាមេរិក) ដល់ ៤៥៩.៤៧៣ លានរៀល (១១៤ លានដុល្លារអាមេរិក) ក្នុងកំឡុងពេលជាមួយគ្នា ។






ទោះបីជាមានគ្រោះទឹកជំនន់ធ្ងន់ធ្ងរក្នុងប្រទេសនៅត្រីមាសទី៣ ក៏ដោយ អនុបាតឥណទានមិនដំណើរការធៀបនឹងឥណទានសរុបជាមធ្យម បានធ្លាក់ចុះពី ១,១៨% ក្នុងឆ្នាំ២០១០ មកត្រឹម ០,២២% ។ ដោយអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា អនុបាតសាធនភាពជាមធ្យម គឺ២១,២៥% និងអនុបាតសន្ទនីយភាព គឺ ៣៩៨,៦៦% ។ លទ្ធភាពរកប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបន្តកើនឡើងជាលំដាប់ ។ ប្រាក់ចំណេញសុទ្ធសរុបក្នុងឆ្នាំ២០១១ មានចំនួន ១១០.១១៧ លានរៀល (២៧,២៦លានដុល្លារអាមេរិក) ដែលកើនឡើងចំនួន ៦៣% ពីដំណាច់ឆ្នាំ២០១០ ។ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងមូលនិធិភាគទុនិកមានចំនួន ៣,៦៤% និង ១៥,១០% រៀងគ្នា ។

## ៤. ការអភិវឌ្ឍក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារ

### ៤.១.ការអភិវឌ្ឍផ្នែកបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជា បានពិនិត្យឡើងវិញនូវបទប្បញ្ញត្តិ និងសារាចរជាច្រើន ដើម្បីសម្រេចបាននូវការត្រួតពិនិត្យឲ្យកាន់តែមានប្រសិទ្ធភាព និងដើម្បីឲ្យស្របតាមការអភិវឌ្ឍក្នុងវិស័យហិរញ្ញវត្ថុនាពេលថ្មីៗនេះ ។ ក្នុងកំឡុងឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជា បានបោះផ្សាយនូវសារាចរមួយពាក់ព័ន្ធនឹងការគណនាមូលនិធិផ្ទាល់សុទ្ធ និងប្រកាសចំនួន ៥ ផ្សេងទៀត រួមមាន ប្រកាសស្ដីពីការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត ប្រកាសស្ដីពីការចែករំលែកព័ត៌មានឥណទាន ប្រកាសស្ដីពីតម្លាភាពក្នុងការផ្ដល់សេវាកម្មឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប្រកាសស្ដីពីអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ និងប្រកាសស្ដីពីការផ្ដល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ។

### ៤.២.ការអភិវឌ្ឍផ្នែកត្រួតពិនិត្យ

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា តែងតែធ្វើការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែង ជាប្រចាំចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីការពារប្រាក់បញ្ញើអតិថិជន រក្សាឲ្យបាននូវសុវត្ថិភាព និងភាពរឹងមាំ និងលើកកម្ពស់ការប្រកួតប្រជែង ដោយយុត្តិធម៌ក្នុងវិស័យធនាគារ ។ វិធីសាស្ត្រត្រួតពិនិត្យ ត្រូវបានផ្លាស់ប្ដូរជាលំដាប់ពីការត្រួតពិនិត្យផ្អែកលើបទប្បញ្ញត្តិ មកជាការត្រួតពិនិត្យផ្អែកលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ។ ដើម្បីពង្រីកនូវលំហូរព័ត៌មាន និងទិន្នន័យ ធនាគារជាតិនៃកម្ពុជាបានកែសម្រួល និងអភិវឌ្ឍឡើងវិញនូវប្រព័ន្ធបញ្ជូនរបាយការណ៍ត្រួតពិនិត្យសម្រាប់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។ ប្រព័ន្ធបញ្ជូនរបាយការណ៍ថ្មីនេះ គឺត្រូវធ្វើឡើងតាមរយៈ Online ដែលអាចផ្ដល់ព័ត៌មានស្ដីពីស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានទាន់ពេលវេលា និងកាន់តែត្រឹមត្រូវ ។ ជាមួយគ្នានេះ ប្រព័ន្ធបញ្ជូនរបាយការណ៍នេះ ក៏ជួយកាត់បន្ថយផងដែរនូវបន្ទុក និងថ្លៃដើម ដោយពាក់ព័ន្ធនឹងការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងជួយឆ្លុះបញ្ចាំងពីការអភិវឌ្ឍរបស់វិស័យធនាគារក្នុងប្រទេសកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងភាពប្រែប្រួលយ៉ាងឆាប់រហ័សនៃឧស្សាហកម្មធនាគារផងដែរ ។

### ៤.៣.ការអភិវឌ្ឍនៃសេវាកម្មនិងផលិតផលហិរញ្ញវត្ថុ

ស្របពេលដែលវិស័យធនាគារបន្តរីកចម្រើនលឿនលឿន ផលិតផល និងសេវាកម្មធនាគាររបស់ធនាគារបានអភិវឌ្ឍជាបន្តបន្ទាប់ផងដែរ ។ ផលិតផលភតិសន្យា និងការទិញជួល (Hire Purchase) ត្រូវបានចាប់ប្រើប្រាស់កាន់តែច្រើនឡើងៗ សម្រាប់ការធ្វើហិរញ្ញប្បទានលើទំនិញប្រើប្រាស់ ។ ម៉ូឌែល Bank-Centric និង Mobile Centric កំពុងមានប្រតិបត្តិការក្នុងប្រទេសកម្ពុជា ។ ទោះជាស្ថិតក្នុងទម្រង់ និងម៉ូឌែលណាក៏ដោយ អាជីវកម្មធនាគារចល័ត ត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនតាមបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីធានាថាអតិថិជនត្រូវបានការពារ ។

### ៤.៤.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ធនាគារជាតិនៃកម្ពុជា បានទទួលស្គាល់ពីភាពចាំបាច់នៃការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យធនាគារ ដើម្បីជួយសម្រួលដល់តួនាទីរបស់វិស័យធនាគារក្នុងការជំរុញកំណើនសេដ្ឋកិច្ច ។ ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា បានជំរុញការធ្វើឲ្យមានភាពប្រសើរឡើងនូវប្រព័ន្ធទូទាត់ថ្នាក់ជាតិមួយ បង្កើតនូវមូលដ្ឋានបទប្បញ្ញត្តិសម្រាប់ទីផ្សារអន្តរធនាគារ និងបានគាំទ្រដល់ការបង្កើតក្រុមហ៊ុនក្រេឌីតប្យូរ៉ូ ដែលគ្រោងនឹងដំណើរការនៅក្នុងឆ្នាំ២០១២ ដើម្បីលើកកម្ពស់មុខងារជាអន្តរការី និងមុខងារគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន ដែលគ្រប់គ្រងដោយបទប្បញ្ញត្តិ ។ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ ត្រូវបានគេរំពឹងថា នឹងជួយសម្រួលផងដែរនូវលំហូឥណទានក្នុងសេដ្ឋកិច្ចតាមរយៈការកាត់បន្ថយនូវភាពមិនស៊ីសង្វាក់គ្នានៃព័ត៌មានរវាងគ្រឹះស្ថានធនាគារ និងអតិថិជន ។

ការពង្រឹងការអនុវត្តគណនេយ្យក្នុងគ្រឹះស្ថានធនាគារ ក៏ត្រូវបានទទួលស្គាល់ថា ជាបង្គោលដ៏សំខាន់មួយនៃការអភិវឌ្ឍវិស័យធនាគារ និងសមាហរណកម្មវិស័យធនាគារនៅក្នុងតំបន់ផងដែរ ។ គ្រឹះស្ថានធនាគារក្នុងប្រទេសកម្ពុជា ត្រូវបានរំពឹងថា នឹងចាប់អនុវត្តស្តង់ដារអន្តរជាតិក្នុងការរាយការណ៍ហិរញ្ញវត្ថុ (IFRS) នៅឆ្នាំ ២០១៦ ខាងមុខនេះ ។ ផែនការឆ្ពោះទៅការអនុវត្តពេញលេញនូវស្តង់ដារអន្តរជាតិ ក្នុងការរាយការណ៍ហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានធនាគារកំពុងស្ថិតនៅក្នុងដំណាក់កាលសិក្សានៅឡើយ ។ ផែនការនេះ នឹងធ្វើឲ្យប្រសើរឡើងនូវការអនុវត្តនាពេលបច្ចុប្បន្នទាំងអាជ្ញាធរត្រួតពិនិត្យធនាគារ ក៏ដូចជា គ្រឹះស្ថានធនាគារ និងនាំឲ្យឆ្ពោះទៅដល់ការកែសម្រួលគោលការណ៍គណនេយ្យ ប្រព័ន្ធព័ត៌មាន ធនធានមនុស្សនិងជំនាញ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ន ។ ការធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងនិយ័តករហិរញ្ញវត្ថុក្នុងប្រទេស ត្រូវបានទទួលស្គាល់ថាជាជំហានដ៏សំខាន់ក្នុងការធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។ វិបត្តិហិរញ្ញវត្ថុពិភពលោក បានជំរុញឲ្យមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងមន្ត្រីត្រួតពិនិត្យដល់ទីកន្លែង និងមន្ត្រីត្រួតពិនិត្យលើឯកសារឲ្យកាន់តែប្រសើរជាងមុន ដើម្បីបញ្ចៀសនូវការកេងចំណេញលើចន្លោះប្រហោងនៃបទប្បញ្ញត្តិ ។

## ៥. ហានិភ័យនិងភាពងាយរងគ្រោះ

### ៥.១.ហានិភ័យឥណទាន

ទោះបីជាបរិមាណឥណទានមានកំណើនខ្ពស់រហូតដល់ ៣៣,៥% នៅដំណាច់ឆ្នាំ២០១១ និងការព្រួយបារម្ភពីគ្រោះមហន្តរាយទឹកជំនន់ចំពោះវិស័យកសិកម្មក៏ដោយ ឥណទានមិនដំណើរការនៅក្នុងប្រព័ន្ធធនាគារបានធ្លាក់ចុះពី ៣,០៥% នៅក្នុងឆ្នាំ២០១០ មកត្រឹម ២,៤៣% ។ ឥណទានមិនដំណើរការក្រោយសំវិធានធនក៏បាន

ធ្លាក់ចុះពី ១,៣៧% មកត្រឹម ១,០៩% ផងដែរ ។ សំវិធានធនសរុបលើឥណទានមិនដំណើរការ នៅតែមានស្ថិរភាព ដែលស្ថិតនៅត្រឹមកម្រិត ៥៥% ។




ឥណទានសម្ព័ន្ធញាតិ ត្រូវបានរាយការណ៍ថា ស្ថិតនៅក្នុងកម្រិតកំណត់នៃបញ្ញត្តិប្រុងប្រយ័ត្ន ១០,៧% ។ ឥណទានហានិភ័យធំសរុបរបស់ធនាគារធៀបមូលនិធិផ្ទាល់សុទ្ធ បានកើនឡើងដល់ ៩៧% ធៀបនឹងឆ្នាំ២០១០ ដែលមានត្រឹមតែ ៨០% ។




ប្រតិបត្តិការលក់រាយ និងលក់ដុំបានស្រូបយកចំណែក ១/៣ (មួយភាគបី) នៃសំពាធឥណទានសរុប ។ ឥណទាននៅតាមវិស័យកម្មន្តសាល សេវាកម្មមិនមែនហិរញ្ញវត្ថុ និងកសិកម្ម នីមួយៗស្រូបយកបានប្រមាណ ៩% នៃសំពាធឥណទានសរុប ។ វិស័យទេសចរណ៍ និងសំណង់ ស្រូបយកបានចំណែកទីផ្សារដូចគ្នាត្រឹមកម្រិត ៧.៤% នៃឥណទានសរុប ។ ទោះបីជាសូចនាករទាំងអស់ បានផ្តល់សញ្ញាណវិជ្ជមានលើប្រតិបត្តិការឥណទាន ការត្រួតពិនិត្យត្រូវបានអនុវត្តយ៉ាងប្រុងប្រយ័ត្នលើកំណើនឥណទានលើវិស័យអចលនទ្រព្យ ។




## ៤.២.ហានិភ័យសន្ទនីយភាព

ទ្រព្យសកម្មងាយស្រួលរបស់គ្រឹះស្ថានធនាគារនៅរក្សាស្ថិរភាពខណៈពេលដែលទ្រព្យអកម្មថ្លឹងរយៈពេលមួយខែមានការកើនឡើង ។ កាតព្វកិច្ចក្រៅតារាងតុល្យការ មានការកើនឡើងទ្វេរដងបើធៀបនឹងឆ្នាំមុន ។ ការអភិវឌ្ឍរបស់ទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន នឹងផ្តល់លទ្ធភាពបន្ថែមទៀតដល់គ្រឹះស្ថានធនាគារក្នុងការគ្រប់គ្រងសន្ទនីយភាព ។









### ៩.៣.ហានិភ័យប្រតិបត្តិការ

វិធានការប្រុងប្រយ័ត្នមួយចំនួនបានដាក់ឲ្យអនុវត្ត ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការដូចជា បទប្បញ្ញត្តិស្តីពីអភិបាលកិច្ច លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប និងការត្រួតពិនិត្យផ្ទៃក្នុង ។ លទ្ធផលកន្លងមកបង្ហាញថា ការគ្រប់គ្រងហានិភ័យ ដែលរួមមាន ហានិភ័យប្រតិបត្តិការផងដែរនោះ គឺមានភាពល្អប្រសើរ ។ ទោះបីជាការគ្រប់គ្រងហានិភ័យមានស្ថានភាពល្អប្រសើរក៏ដោយ វិធានការប្រុងប្រយ័ត្នបន្ថែមទៀត ជាពិសេស តម្រូវការដើមទុនសម្រាប់គ្រប់គ្រងហានិភ័យប្រតិបត្តិការកំពុងស្ថិតនៅក្នុងការពិចារណា ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃទំហំ និងប្រភេទប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ ។

### ៩.៤.លទ្ធភាពស្វែងរកប្រាក់ចំណេញ

លទ្ធភាពស្វែងរកប្រាក់ចំណេញនៅក្នុងវិស័យធនាគារមានការកើនឡើងគួរឲ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំមុន ។ ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មជាមធ្យមបានកើនដល់ ១.៨៩% ខណៈដែលប្រាក់ចំណេញធៀបដើមទុនសម្រេចបាន ៩.០២% នៅដំណាច់ឆ្នាំ២០១១ ។




### ៨.៨.ដើមទុន

អនុបាតសាធនភាពបានធ្លាក់ចុះពី ៣១,៣៨% នៅដំណាច់ឆ្នាំ២០១០ មកត្រឹម ២៦,២៣% នៅដំណាច់ឆ្នាំ២០១១ ប៉ុន្តែកម្រិតអនុបាតនេះ នៅតែស្ថិតនៅលើកម្រិតបទបញ្ញាប្រុងប្រយ័ត្ន និងសញ្ញាណដែលគួរឲ្យព្រួយបារម្ភ ។ ការថយចុះនៃកម្រិតអនុបាតសាធនភាព គឺបណ្តាលមកពីការកើនឡើងយ៉ាងខ្លាំងនូវការផ្តល់ឥណទាន ហើយការកើនឡើងនូវការផ្តល់ឥណទាននេះ នឹងធ្វើឲ្យកើនឡើងនូវទ្រព្យសកម្មថ្លឹងហានិភ័យ ។ ដើមទុនថ្នាក់ទីមួយមានកម្រិត ២៤,៩៦% ដែលបានបង្ហាញពីស្ថិរភាពនៃភាពរឹងមាំនៃមូលដ្ឋានដើមទុនរបស់ធនាគារនៅក្នុងឆ្នាំ២០១១ ។




## ៦. បញ្ហា និងការប្រឈម

ទោះបីសមិទ្ធិផលចំបងៗត្រូវបានសម្រេចក្នុងពេលកន្លងមកក៏ដោយក៏បញ្ហាប្រឈមនៅតែមានក្នុងការអភិវឌ្ឍនិងការរក្សាស្ថិរភាពវិស័យធនាគារ ។ បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យលើបទបញ្ញាប្រុងប្រយ័ត្នទាំងឡាយ ដើម្បីកាត់បន្ថយនូវលទ្ធភាពក្នុងការគេចវេសមិនអនុវត្តតាមបទប្បញ្ញត្តិ ហើយក្នុងពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានពិនិត្យ និងវាយតម្លៃពីភាពចាំបាច់ក្នុងការដាក់ឲ្យអនុវត្តបទបញ្ញាប្រុងប្រយ័ត្នបន្ថែម

ផងដែរ ។ បទប្បញ្ញត្តិប្រុងប្រយ័ត្នសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងហានិភ័យឥណទាន និងហានិភ័យសន្ទនីយភាព ចាំបាច់ត្រូវធ្វើការពិនិត្យឡើងវិញ ចំណែកឯបទប្បញ្ញត្តិទាក់ទងនឹងហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ចាំបាច់ត្រូវដាក់ឲ្យអនុវត្តបន្ថែមទៀត ។

ការកសាងសមត្ថភាពបុគ្គលិក នៅតែជាអាទិភាពចំបងរបស់ធនាគារជាតិនៃកម្ពុជាដដែល ។ ធនាគារជាតិនៃកម្ពុជា ទទួលស្គាល់អំពីតម្រូវការចាំបាច់ក្នុងការមានធនធានមនុស្សគ្រប់គ្រាន់ និងពេលវេលាសម្រាប់ការកសាងសមត្ថភាព និងជំនាញ ។ ការរៀបចំកម្មវិធីកសាងសមត្ថភាពជាការងារអាទិភាព ដើម្បីសម្រេចបាននូវធនធានមនុស្សដែលមានគុណភាព និងសមត្ថភាព ។

## ៧. សេចក្តីសន្និដ្ឋាន

ហានិភ័យក្នុងប្រព័ន្ធធនាគារនៅតែស្ថិតក្នុងកម្រិតមួយ ដែលអាចគ្រប់គ្រងបាន ទោះបីជាមានការព្រួយបារម្ភខ្លះអំពីហានិភ័យឥណទាន និងហានិភ័យសន្ទនីយភាព ។ ប្រតិបត្តិការនៅក្នុងវិស័យធនាគារមានប្រក្រតីភាពឡើងវិញ ហើយរាល់សញ្ញាណទាំងឡាយបានបង្ហាញពីទស្សនាទានវិជ្ជមានទាំងល្បឿន និងទំហំនៃការរីកចម្រើន ។ មុខងារអន្តរការីយកម្មបន្តរីកដុះដាលជាយ៉ាងលឿន និងជំរុញដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅ និងទូលំទូលាយ ។

# ឧបសម្ព័ន្ធទី ១

## ទិន្នន័យរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ឆ្នាំ២០១១

### ចំណាំ: ទិន្នន័យទាំងអស់មិនបានធ្វើសវនកម្ម និងរាយការណ៍ដោយ
### គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

(សូមមើលនៅឧបសម្ព័ន្ធទី១ ផ្នែកភាសាអង់គ្លេស)

## ឧបសម្ព័ន្ធ ២ ក

## អត្រាការប្រាក់លើការឲ្យខ្ចីចងការ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០១១)

(អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ឥណទានជារៀល | | | | | ឥណទានជាដុល្លារ | | | | | ឥណទានជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | ថ្ងៃ | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារ អេស៊ីលីដា | | | 12.00% | 12.00% | 16.80% | | | 12.00% | 12.00% | 12.96% | | | 12.00% | 12.00% | 16.80% |
| 2 | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | | | | | | | 24.68% | 24.68% | 24.68% | 24.68% | | | | | |
| 3 | ធនាគារ កាណាឌីយ៉ា ចំកាត់ | | 24.00% | 24.00% | 24.00% | 24.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 4 | ធនាគារ អេ អ៊ិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា | | | | | | | | | | 8.25% | | | | | |
| 5 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | | 18.00% | 18.00% | 18.00% | 18.00% | | 18.00% | 18.00% | 18.00% | 18.00% | | | | | |
| 6 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | | | | | | | | | | 10.00% | | | | | 23.00% |
| 7 | ធនាគារ មេយប៊ែង | | | | | | | | | | 11.00% | | | | | |
| 8 | ធនាគារ វឌ្ឍនៈ | | | | | | | 8.50% | 9.02% | 9.00% | 10.80% | | | | | |
| 9 | ធនាគារ សហពាណិជ្ជ ក.អ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 10 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | | | | | | | 14.00% | 15.00% | 16.00% | 18.00% | | | | | |
| 11 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | | | | | | | 11.25% | 11.25% | 11.25% | 11.25% | | 11.25% | 11.25% | 11.25% | 11.25% |
| 12 | ធនាគារ ពាណិជ្ជកម្មទី១ | | | | | | | 12.00% | 12.00% | 12.00% | 12.00% | | | | | |
| 13 | ធនាគារ ក្រុងថៃមហាជន ចំកាត់ | | | | | | | | | | 13.00% | | | | | 10.00% |
| 14 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 15 | ធនាគារ មេគង្គកម្ពុជា | | | | | | | 14.40% | 14.40% | 14.40% | 14.40% | | | | | |
| 16 | ធនាគារ សាជីវកម្មសឹង្ហបូរី ចំកាត់ | | | | | | | | 15.00% | 15.00% | 15.00% | | | | | |
| 17 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | | | | | 13.00% | | | | | |
| 18 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | | | | | | | | | | 16.00% | | | | | |
| 19 | ធនាគារ ប៊ូយ៉ុងខ្មែរ | | | | | | | | | | 15.00% | | | | | |
| 20 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | | 15.00% | 15.00% | 15.00% | 15.00% | | | | | |
| 21 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | | | | | | | 14.00% | 14.00% | 14.00% | 14.00% | | | | | |
| 22 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | | | | | | | | | | 14.00% | | | | | |
| 23 | ធនាគារ ហ្វង ឌីប៊ីអេស | | | | | | | | | | 12.00% | | | | | |
| 24 | ធនាគារ ភ្នំពេញពាណិជ្ជ | | | | | | | | | | 19.00% | | | | | |
| 25 | ធនាគារ សាខម | | 11.00% | 11.00% | 11.00% | 11.00% | | 11.00% | 11.00% | 11.00% | 11.00% | | | | | |
| 26 | ធនាគារ ស៊ីអាយអិមប៊ី | | | | | | | 12.00% | 12.00% | 12.00% | 12.00% | | | | | |
| 27 | ធនាគារ អាហ្គ្រីប៊ែង សាខាកម្ពុជា | | 16.80% | 16.80% | 16.80% | 16.80% | | 16.20% | 16.20% | 16.20% | 16.20% | | | | | |
| 28 | ធនាគារ ចិន សាខាភ្នំពេញ | | | | | | | | | | 12.00% | | | | | |
| 29 | ធនាគារ ឯកទេសខេមខូ លីមីតធីត | | | | | | | | | | 15.00% | | | | | |
| 30 | ធនាគារ អភិវឌ្ឍន៍ជនបទ | | | | | 15.00% | | | | | 12.00% | | | | | |
| 31 | ធនាគារ ឯកទេស ភី អេច អេស អឹម អ៊ី ចំកាត់ | | | | | | | | | | 18.00% | | | | | |
| 32 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | | | 18.00% | | | | | |
| 33 | ធនាគារ ឯកទេស អានកូ | | | | | | | | | | 14.99% | | | | | |
| 34 | ធនាគារ ឯកទេសតូម៉ាតូ | | | | | | | | | | 15.13% | | | | | |
| 35 | ធនាគារ ឯកទេសអង្គរ កាពីតាល | | | | | | | 24.00% | 24.00% | 24.00% | 24.00% | | | | | |
| **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | | | **22.09%** | **16.99%** | **16.99%** | **19.35%** | | **18.57%** | **16.35%** | **16.38%** | **15.36%** | | **11.25%** | **11.98%** | **11.98%** | **17.84%** |
| **មធ្យមភាគអត្រាការប្រាក់** | | | **17.45%** | **16.36%** | **16.36%** | **16.93%** | | **15.22%** | **15.09%** | **15.15%** | **14.76%** | | **11.25%** | **11.63%** | **11.63%** | **15.26%** |

# ឧបសម្ព័ន្ធ ២ខ

## អត្រាការប្រាក់លើប្រាក់បញ្ញើ ( ប្រាក់រៀល និងរូបិយប័ណ្ណ )

(ប្រចាំខែធ្នូ ឆ្នាំ២០១១) (អត្រាប្រចាំឆ្នាំ)

| ល.រ | ឈ្មោះធនាគារ | ប្រាក់បញ្ញើជារៀល | | | | | ប្រាក់បញ្ញើជាដុល្លារ | | | | | ប្រាក់បញ្ញើជារូបិយប័ណ្ណផ្សេងៗ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | | សំចៃ | ប្រាក់បញ្ញើមានកាលកំណត់ | | | |
| | | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ | | ១ខែ | ៣ខែ | ៦ខែ | ១២ខែ |
| 1 | ធនាគារ អេស៊ីលីដា | 1.25% | 3.00% | 5.00% | 6.00% | 6.50% | 0.50% | 1.50% | 2.50% | 3.75% | 4.25% | 0.50% | 2.00% | 2.50% | 3.25% | 3.75% |
| 2 | ធនាគារ កម្ពុជាសាធារណៈ ចំកាត់ | 0.50% | | | | | 0.50% | 1.75% | 2.50% | 3.50% | 4.25% | 0.50% | | | | |
| 3 | ធនាគារ កាណាឌីយ៉ា ចំកាត់ | 2.00% | | 5.00% | 6.00% | 7.00% | 0.75% | 2.00% | 2.50% | 3.50% | 4.75% | | | | | |
| 4 | ធនាគារ អេ អ៊ិន ហ្សេត រូយ៉ាល់ កម្ពុជា | 0.50% | 3.25% | 3.50% | 4.00% | 5.50% | 0.25% | 1.05% | 1.45% | 2.75% | 3.75% | 0.40% | 0.50% | 0.65% | 0.75% | 0.95% |
| 5 | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | 1.50% | | 4.50% | 5.50% | 6.50% | 0.75% | 1.00% | 2.50% | 3.50% | 4.75% | | | | | |
| 6 | ធនាគារ អភិវឌ្ឍន៍និងវិនិយោគកម្ពុជា ភីអិលស៊ី | 2.00% | 3.55% | 4.60% | 5.55% | 6.50% | 1.00% | 2.50% | 3.00% | 4.00% | 4.85% | | | | | |
| 7 | ធនាគារ មេយប៊ែង | | | | | | 0.50% | 1.50% | 2.25% | 3.25% | 4.25% | | | | | |
| 8 | ធនាគារ វឌ្ឍនៈ | | | | | | 0.50% | 1.50% | 2.00% | 3.00% | 3.50% | | | | | |
| 9 | ធនាគារ សហពាណិជ្ជ ក.អ | | | | | | 1.00% | 2.50% | 3.50% | 4.50% | 5.50% | | | | | |
| 10 | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 0.75% | | | | | 0.75% | 2.50% | 3.50% | 4.50% | 5.50% | | | | | |
| 11 | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ | 0.10% | | 1.00% | | | 0.10% | | 1.00% | 1.00% | 1.00% | 0.10% | | 1.00% | | |
| 12 | ធនាគារ ពាណិជ្ជកម្មទី១ | | | | | | 0.40% | 1.00% | 1.20% | 1.40% | 1.80% | | | | | |
| 13 | ធនាគារ ក្រុងថៃមហាជន ចំកាត់ | | | | | | 0.10% | | 0.50% | 0.75% | 1.00% | | | | | |
| 14 | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | | | | | | 2.00% | 2.50% | 3.50% | 4.50% | 5.50% | | | | | |
| 15 | ធនាគារ មេគង្គកម្ពុជា | 3.50% | | | | | 2.00% | 2.25% | 2.75% | 3.25% | 3.50% | 2.00% | | | | |
| 16 | ធនាគារ សាជីវកម្មសឹង្ហបូរី ចំកាត់ | | | | | | 0.50% | | 2.50% | 3.00% | 4.00% | | | | | |
| 17 | ធនាគារ ឥណ្ឌា សាខាភ្នំពេញ | | | | | | 0.75% | 1.00% | 2.25% | 3.00% | 4.00% | | | | | |
| 18 | ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី អិល ស៊ី | 3.00% | 1.00% | 2.00% | 3.00% | 4.50% | 3.00% | 1.00% | 2.00% | 3.00% | 4.50% | | | | | |
| 19 | ធនាគារ ប៊ូយ៉ុងខ្មែរ | 1.00% | 3.00% | 4.00% | 5.00% | 6.00% | 0.50% | 1.50% | 2.50% | 3.00% | 3.50% | | | | | |
| 20 | ធនាគារ ស៊ិនហាន ខ្មែរ | | | | | | 0.25% | 1.25% | 1.25% | 3.20% | 3.50% | | | | | |
| 21 | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 0.70% | 1.70% | 2.50% | 3.20% | 3.60% | 0.50% | 1.20% | 2.00% | 2.70% | 3.10% | | | | | |
| 22 | ធនាគារ អូ អេស ខេ ឥណ្ឌូឆៃណា | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.50% | 2.25% | 2.75% | 3.50% | 4.75% | | | | | |
| 23 | ធនាគារ ហ្វង ឌីប៊ីអេស | | | | | | 1.00% | 2.25% | 2.75% | 3.75% | 4.25% | | | | | |
| 24 | ធនាគារ ភ្នំពេញពាណិជ្ជ | | | | | | 1.20% | 2.50% | 4.20% | 5.20% | 6.20% | | | | | |
| 25 | ធនាគារ សាខម | 1.00% | 3.00% | 4.00% | 5.00% | 6.00% | 0.50% | 2.00% | 3.00% | 4.00% | 5.00% | | | | | |
| 26 | ធនាគារ ស៊ីអាយអិមប៊ី | | | | | | 1.50% | 2.25% | 2.50% | 3.50% | 4.25% | | | | | |
| 27 | ធនាគារ អាហ្វ្រីប៊ែង សាខាកម្ពុជា | 1.25% | 3.00% | 4.00% | 4.25% | 5.00% | 1.00% | 1.50% | 2.50% | 3.00% | 3.50% | | | | | |
| 28 | ធនាគារ ចិន សាខាភ្នំពេញ | 0.13% | 0.13% | 0.13% | 0.13% | 0.13% | 0.50% | 1.25% | 2.25% | 2.75% | 3.25% | | | | | |
| 29 | ធនាគារ ឯកទេសខេមខូ លីមីតធីត | | | | | | | | | | | | | | | |
| 30 | ធនាគារ អភិវឌ្ឍន៍ជនបទ | 1.50% | 3.50% | 4.00% | 5.00% | 6.00% | 1.00% | 3.00% | 3.50% | 4.00% | 5.00% | | | | | |
| 31 | ធនាគារ ឯកទេស ភី អេច អែស អឹម អ៊ី ចំកាត់ | | | | | | | | | | | | | | | |
| 32 | ធនាគារ ឯកទេសវិនិយោគទីមួយ | | | | | | | | | | | | | | | |
| 33 | ធនាគារ ឯកទេស អានកូ | | | | | | | | | | | | | | | |
| 34 | ធនាគារ ឯកទេសតូម៉ាតូ | | | | | | | | | | | | | | | |
| 35 | ធនាគារ ឯកទេសអង្គរ កាពីតាល | | | | | | | | | | | | | | | |
| | **មធ្យមភាគអត្រាការប្រាក់ក្រោយការថ្លឹង** | **1.18%** | **2.86%** | **4.33%** | **5.28%** | **6.16%** | **0.63%** | **1.65%** | **2.39%** | **3.43%** | **4.29%** | **0.48%** | **1.49%** | **1.83%** | **2.40%** | **2.80%** |
| | **មធ្យមភាគអត្រាការប្រាក់** | **1.30%** | **2.60%** | **3.45%** | **4.43%** | **5.33%** | **0.86%** | **1.79%** | **2.43%** | **3.27%** | **4.03%** | **0.70%** | **1.25%** | **1.38%** | **2.00%** | **2.35%** |

# ប្រព័ន្ធធនាគារកម្ពុជា

*ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១១*

## ធនាគារជាតិនៃកម្ពុជា

### ៣១ ធនាគារពាណិជ្ជ

#### ៩ សាខាធនាគារបរទេស

១-ធនាគារ ពាណិជ្ជ ទី១
២-ធនាគារ ក្រុងថៃ
៣-ធនាគារ មេយប៊ែង
៤-ធនាគារ ឥណ្ឌា
៥-ធនាគារ កសិកកម្ម និងអភិវឌ្ឍន៍ ជនបទវៀតណាម សាខាកម្ពុជា
៦-ធនាគារ ចិន សាខាភ្នំពេញ
៧-ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល សាខាភ្នំពេញ
៨-ធនាគារ អាយ ស៊ី ប៊ី ស៊ី
៩-ធនាគារ អ៊ឹម ប៊ី

#### ១៣ បង្កើតឡើងក្នុងស្រុក

១-ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស
២-ធនាគារ វឌ្ឍនៈអាស៊ី
៣-ធនាគារ កម្ពុជាអាស៊ី
៤-ធនាគារ កាណាឌីយ៉ា
៥-ធនាគារ កម្ពុជាមេគង្គ
៦-សាជីវកម្ម ធនាគារ សឹង្ហបូរី
៧-ធនាគារ សហពាណិជ្ជ
៨-ធនាគារ វឌ្ឍនៈ
៩-ធនាគារ អេស៊ីលីដា
១០-ធ.វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា
១១-ម៉ារ៉ូហាន់ ធនាគារ ជប៉ុន
១២-ធនាគារ ប៉ូយុងខ្មែរ
១៣-ធនាគារ ភ្នំពេញពាណិជ្ជ

#### ៩ បុត្តសម្ព័ន្ធធនាគារ

១-ធនាគារ កម្ពុជាពាណិជ្ជ
២-ធនាគារ កម្ពុជាសាធារណៈ
៣-ធនាគារ អេអ៊ិនហ្សែតរ៉ូយ៉ាល់
៤-ធនាគារ ស៊ិនហានខ្មែរ
៥-ធនាគារ គូកមីន កម្ពុជា
៦-ធនាគារអូអេសខេឥណ្ឌូឆាយណា
៧-ធនាគារ ហ្វង ឌីប៊ីអេស ពាណិជ្ជ (១៧)
៨-ធនាគារ ស៊ី អាយ អ៊ឹមប៊ី (២០)
៩-ធនាគារ សាយហ្គន ធៀងទិន ខេមបូឌា ភីអិលស៊ី ( ១៦)

### ៧ ធនាគារឯកទេស

#### ១ ធនាគាររដ្ឋ

១-ធនាគារឯកទេស អភិវឌ្ឍន៍ជនបទ

#### ៦ ធនាគារឯកជន

១-ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី
២-ធនាគារឯកទេស វិនិយោគទី១
៣-ធនាគារឯកទេស អានកូ
៤-ធនាគារឯកទេស តូមាតូ
៥-ធនាគារឯកទេស អង្គរ កាពីតាល
៦-ធនាគារឯកទេស ខេមខូ

### ២ ការិយាល័យតំណាង

១-ធនាគារ ស្តង់ដារឆាទីរ៉េត
២-ធនាគារវិនិយោគនិងអភិវឌ្ឍន៍នៃវៀតណាម

### គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

#### ៣២ មានអាជ្ញាប័ណ្ណ

១-អម្រឹត
២-ហត្ថាកសិករ
៣-ធនាគារភូមិ ខេមបូឌា
៤-ស្ថាបនា
៥-សីលានិធិ
៦-អង្គរ មីក្រូហិរញ្ញវត្ថុ
៧-វីសិនហ្វាន់ ខេមបូឌា
៨-ក្រេឌីត
៩-ប្រាសាក់ ម៉ាយក្រូហ្វាយនែន
១០-សមាគមមូលនិធិសហភាពអភិឌ្ឍន៍កសិករ
១១-អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទកម្ពុជា
១២-ម៉ាក់ស៊ីម៉ា
១៣-ឥណទានពលរដ្ឋរុងរឿង
១៤-សាមិក
១៥-ឥណទានអភិវឌ្ឍន៍ប្រជាជន
១៦-ហ្វាមើរ ហ្វាយនែន
១៧-ហ្វ្រីន សេនត្រល ម៉ាយក្រូហ្វាយនែន
១៨-ហ្វឹស ហ្វាយនែន
១៩-វ៉ាយស៊ីភី ម៉ាយក្រូហ្វាយនែន
២០-ខេម ខាប់ភីថល
២១-សំរិទ្ធិស័ក មីក្រូហិរញ្ញវត្ថុ
២២-ខេមា មីក្រូហិរញ្ញវត្ថុ
២៣-អង្គរ អេស៊ីអ៊ីស្តារក្រេឌីត
២៤-ខេមរៈ
២៥-ប្រាយ៍ម អិមអេហ្វ
២៦-សូណាត្រា
២៧-ម៉្ហូះ ហ្វាយនែន
២៨-ចំរើន ម៉ាយក្រូហ្វាយនែន
២៩-អាក់ទីវ ភីភល
៣០-បាយ័ន ក្រេឌីត
៣១-អ៊ីអន ម៉ាយក្រូហ្វាយនែន
៣២-បរិបូរណ៍

### ២១ សាខាធនាគារជាតិនៅតាមខេត្ត

១-ក្រុងភ្នំពេញ
២-កំពង់ចាម
៣-ព្រះសីហនុ
៤-សៀមរាប
៥-បាត់ដំបង
៦-បន្ទាយមានជ័យ
៧-ស្វាយរៀង
៨-កណ្តាល
៩-កំពត
១០-កំពង់ធំ
១១-ពោធិសាត់
១២-កំពង់ស្ពឺ
១៣-កោះកុង
១៤-រតនៈគីរី
១៥-ព្រៃវែង
១៦-តាកែវ
១៧-កំពង់ឆ្នាំង
១៨-ព្រះវិហារ
១៩-ក្រចេះ
២០-ស្ទឹងត្រែង
២១-មណ្ឌលគីរី

### អាជីវកម្មប្តូរប្រាក់

ភ្នំពេញ:
-អាជ្ញាប័ណ្ណ ៣៧
-លិខិតអនុញ្ញាត ៤០
-អាជ្ញាប័ណ្ណ ២
-លិខិតអនុញ្ញាត១៥៤៨

## អង្គការក្រៅរដ្ឋាភិបាលដែលបានចុះបញ្ជី

## ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១

| ល.រ | ឈ្មោះអង្គការ | ល.រ | ឈ្មោះអង្គការ |
|---|---|---|---|
| 1 | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅកម្ពុជា | 16 | សមាគមអភិវឌ្ឍន៍សណ្តែកសៀងតាអុង |
| 2 | អង្គការអភិវឌ្ឍន៍សង្គមជនបទ | 17 | អង្គការសង្គហអភិវឌ្ឍន៍កម្ពុជា |
| 3 | អង្គការអភិវឌ្ឍន៍ជនបទខ្មែរ | 18 | សមាគមសំណាងអភិវឌ្ឍន៍ជនបទ |
| 4 | អង្គការល្វថេវ៉ាន បំរើពិភពលោក | 19 | អង្គការបណ្តាញសេដ្ឋកិច្ចកម្ពុជា |
| 5 | អង្គការឥណទានលប់បំបាត់ភាពក្រីក្រនៅកម្ពុជា | 20 | អង្គការទ្រទ្រង់សហគមន៍បង្កើនអភិវឌ្ឍន៍ |
| 6 | សមាគមជួយកសិករ | 21 | វិទ្យាស្ថានសន្តិភាពនិងអភិវឌ្ឍន៍ |
| 7 | សមាគមសុខមាលភាពស្ត្រីខេត្តក្រចេះ | 22 | អង្គការច័ន្ទ សុខសាន្ត |
| 8 | អង្គការក្រុមការងារសេដ្ឋកិច្ចថ្មី | 23 | អង្គការសម្បុរស |
| 9 | គំរោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ | 24 | អង្គការអភិវឌ្ឍន៍របរចិញ្ចឹមជីវិតកសិករ |
| 10 | សហព័ន្ធសហគមន៍សន្សំប្រាក់កម្ពុជា | 25 | សមាគមអភិវឌ្ឍន៍ភូមិ |
| 11 | សមាគមផ្តើមគំនិតពាណិជ្ជកម្ម | 26 | ស៊ី ខេ អិម អេហ្វ ជី (ខេមបូឌា) |
| 12 | សមាគមជាតិទ្រទ្រង់កសិផល | 27 | អង្គការលោកគ្រូ |
| 13 | សមាគមអភិវឌ្ឍន៍តំបន់ពាយ័ព្យ | 28 | អង្គការសមាគមកសិករខ្មែរបាត់ដំបង |
| 14 | សមាគមអភិវឌ្ឍន៍កសិកម្មនិងទេសចរណ៍ | 29 | អង្គការអភិវឌ្ឍន៍គ្រួសារក្រីក្រ ជាមួយប្រព័ន្ធកសិកម្ម នៅប្រទេសកម្ពុជា |
| 15 | ស៊ី អាយ ស៊ី អេម-កម្ពុជា | | |